## ១- ឈ្មោះ និង ការចាត់ថ្នាក់នៃប្រភេទឈើ

ឈ្មោះក្នុងស្រុក : **នាងនួន**

ឈ្មោះវិទ្យាសាស្ត្រ : ***Dalbergia oliveri* Gramble ex Prain**

អំបូរ : **Leguminosae**

ចំណាត់ថ្នាក់ជាតិ : **ឈើប្រណីត**

## ២- ការរាយប៉ាយក្នុងធម្មជាតិ និង ទីកន្លែងដុះដាល

តាមឯកសារដែលបោះពុម្ពនៅឆ្នាំ ២០០០ ដោយក្រសួងកសិកម្ម និង អភិវឌ្ឍន៍ជនបទនៃប្រទេសវៀតណាម ឈើនាងនួនមានឈ្មោះវិទ្យាសាស្ត្រដែលគេនិយមប្រើប្រាស់សព្វថ្ងៃថា: *Dalbergia oliveri* ហើយវាក៏មានឈ្មោះវិទ្យាសាស្ត្រដទៃទៀតដូចជា *Dalbergia bariensis, D. mammosa, D. dongnaiensis* ។

នាងនួនជាប្រភេទឈើធំ ដែលឃើញមានដុះក្នុងតំបន់អាស៊ីអគ្នេយ៍ ក្នុងប្រទេសកម្ពុជា ថៃ ឡាវ និង វៀតណាមភាគខាងត្បូង។ នាងនួនជាប្រភេទឈើចូលចិត្តពន្លឺ វាច្រើនដុះតែឯង ឬជាជ្រុំៗដែលមានពី ៥-១០ ដើម ក្នុងព្រៃស្រោងឬពាក់កណ្តាលស្រោងនៃតំបន់ត្រូពិកដែលមានរយៈកំពស់រហូតដល់ ១២០០ម ធៀបនឹងនីវ៉ូសមុទ្រ ហើយច្រើនដុះលាយជាមួយដើមឈើ គោល *(Albizia chinensis)* កកោះ *(Sindora siamensis)* ក្រញូង *(Dalbergia cochinchinensis)* និង ឈើទាលទឹក *(Dipterocarpus alatus)* ។ នាងនួងលូតលាស់ល្អលើដីក្រហម-ត្នោត ដីសំបូរជីជាតិ ឬដីសើមតាមបណ្តោយដងអូរ។ នៅប្រទេសកម្ពុជា ឈើនាងនួនមានដុះដោយធម្មជាតិ នៅក្នុងខេត្តពោធិ៍សាត់ សៀមរាប ព្រះវិហារ កំពង់ធំ ស្ទឹងត្រែង រតនគិរី ក្រចេះ ។ល។ ដោយសារតែតំរូវការប្រើប្រាស់ និង តម្លៃនៅលើទីផ្សារខ្ពស់ ឈើប្រភេទនេះត្រូវបានចាត់ទុកជាប្រភេទដែលកំពុងរងការគំរាមកំហែងខ្លាំង និងត្រូវការការពារជាបន្ទាន់ ហើយបើគ្មានវិធានការជាបន្ទាន់ទេ កូនចៅជំនាន់ក្រោយនឹងមិនស្គាល់ប្រភេទឈើនាងនួនទៀតឡើយ។ ក្នុងតារាងចាត់ថ្នាក់ប្រភេទឈើកម្ពុជាដែលកំពុងរងការគំរាមកំហែង ប្រភេទនាងនួននេះស្ថិតក្នុងលេខរៀងលើគេបង្អស់ ហើយនៅក្នុងបញ្ជីប្រភេទឈើដែលកំពុងរងការគំរាមកំហែងរបស់ IUCN ក៏មានប្រភេទឈើនេះដែរ។ នៅឆ្នាំ២០០១ គំរោងគ្រាប់ពូជឈើកម្ពុជានៃរដ្ឋបាលព្រៃឈើបានរៀបចំប្រភពគ្រាប់ពូជឈើនាងនួន ក្នុងព្រៃធម្មជាតិ ដែលមានទីតាំងឋិតនៅក្នុងឃុំប៉ាលហាល ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ និងមានចំងាយប្រហែល ១២ គ.ម នាទិសនិរតី ទីរួមខេត្ត។ ចំការពូជនេះមានទំហំ ១២,៥ហ.ត និង មានដើមនាងនួនចំនួន ៧៨ ដើម។

## ៣- ការប្រើប្រាស់

នៅប្រទេសយើង នាងនួនត្រូវបានចាត់ថ្នាក់ជាប្រភេទឈើប្រណីត ហើយមានតម្លៃយ៉ាងខ្ពស់នៅលើទីផ្សារ។ សាច់ឈើរឹងល្អ មានពណ៌ក្រហម-ក្រម៉ៅ និង មានសសៃឆ្នូតតូចៗ។ ប្រភេទនេះភាគច្រើនត្រូវបានប្រើប្រាស់ក្នុងការផលិតគ្រឿងសង្ហារឹម វត្ថុចម្លាក់ ។ល។

## ៤- លក្ខណៈរុក្ខសាស្ត្រ

**-ដើម:** នាងនួនជាដើមឈើមានទំហំមធ្យម។ ជាទូទៅ ដើមឈើពេញវ័យមានកំពស់សរុប ១៨-២២ម ក្នុងនោះមានកំពស់ភាគដើមប្រវែងពី ៨-១៥ម ដោយទំរង់ដើមប្រែប្រួលទៅតាមលក្ខណៈនៃទីកន្លែង ហើយទំហំអង្កត់ផ្ចិតប្រែប្រួលពី ៥០-៩០ ស.ម។ នៅកន្លែងដែលមានដីជ្រៅធូរ និង មានជីជាតិល្អ ដើមនាងនួងមានរាងជាស៊ីឡាំង ហើយត្រង់ស្រឡូនល្អ ចំណែកនៅលើដីខ្សត់ជីជាតិ និង សំបូរដោយគ្រួស ដើមច្រើនវៀចកោងមានស្នាមពក-ផត ជួនកាលបែកជាចំពាមផង។ សំបកនាងនួនមិនប្រេះបែកក្រហែងទេ វាមានពណ៌ប្រផេះ-ត្នោត និង ជួនកាលមានចំណុចពិណសលាយលឿងផងដែរ។

**-ស្លឹក:** ភាគកំពូលនៃកន្សោមស្លឹកអាចមានកំពស់ ៥-៩ម។ ស្លឹកនាងនួនជាស្លឹកសមាសស្លាបទោល មានបន្ទះស្លឹកឆ្លាស់គ្នា ជាទូទៅមានចំនួនពី ១៣-១៧ និងកំរឃើញមានចំនួន ៩-១១ ឬ១៩-២១ ណាស់។ បន្ទះស្លឹកមានបណ្តោយ ១១-១៣ ស.ម។

**-ផ្កា:** ផ្កាជាចង្កោម មានពណ៌សដុះចេញពីក្លៀក(អ័ក្ស)ខាងចុងនៃកូនមែក មានបណ្តោយ ១០-២០ស.ម និងទទឹង ៧-១៥ស.ម ភ្ជាប់ដោយទងមួយវែងប្រកបដោយរោមវែងៗ។

**-ផ្លែ:** ផ្លែជាកួរ មានសំបកស្តើងរលោងមានទងវែង ពេលស្ងួតរឹង មានប្រវែងជាមធ្យម ៦-១០ស.ម និងទទឹង ១,៥-២,៥ស.ម។ ក្នុងមួយកួរមានគ្រាប់ចំនួន ១-២ កំរមាន ៣គ្រាប់ណាស់ ហើយជាប្រភេទផ្លែស្ងួត មិនប្រេះឱ្យគ្រាប់ធ្លាក់ចេញទេ នៅកន្លែងដែលមានគ្រាប់ កួររបស់ផ្លែឡើងប៉ោង។

**-គ្រាប់:** គ្រាប់នាងនួនជាប្រភេទគ្រាប់ទុកបានយូរ (Orthodox) និងមានរាងសំប៉ែតដូចគ្រាប់ក្រញូងតែមានទំហំធំជាង មានពណ៌កាហ្វេ មានបណ្តោយ ១០ ម.ម និងទទឹង ៦ម.ម។ តាមពតិមានពីបន្ទប់ពិសោធន៍គំរោងគ្រាប់ពូជឈើកម្ពុជា ក្នុងមួយគីឡូក្រាមគ្រាប់សុទ្ធមានចំនួនប្រមាណ ៦ ១០០គ្រាប់ ហើយពេលបេះភ្លាមគ្រាប់មានសំណើមដំបូង ១៤%។





## ៥- រដូវចេញផ្កា ផ្លែ

នៅប្រទេសកម្ពុជានាងនួនចេញផ្កានៅខែ ឧសភា-កក្កដា និងផ្លែទុំនៅចន្លោះខែ វិច្ឆិកា-ធ្នូ។

## ៦- ការបេះប្រមូលគ្រាប់ពូជ

ផ្លែនាងនួនទុំនៅពេលណាដែលសំបកផ្លែប្រែពណ៌ពីខៀវទៅជាពណ៌ត្នោតចាស់។ គេគួរតែបេះប្រមូលផ្លែនាងនួនឱ្យបានរហ័សនៅពេលដែលដឹងថា